ថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០០៨

## លិខិតអញ្ជើញចូលរួមសន្និសីទសារព័ត៌មានស្តីពីលទ្ធផលនៃការត្រួតពិនិត្យពិសេស

គណៈគ្រប់គ្រងគម្រោងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសូមអញ្ជើញអ្នកសារព័ត៌មានចូលរួមក្នុងសន្និសីទសារព័ត៌មានស្តីពីលទ្ធផលនៃការត្រួតពិនិត្យលើការគ្រប់គ្រងធនធានមនុស្ស។
សន្និសីទសារព័ត៌មាននេះនឹងរៀបចំឡើងនៅ:

វេលាម៉ោង ៩:០០ ដល់ ១០:៣០ ព្រឹក ថ្ងៃសុក្រ ទី២៥ ខែមេសា ឆ្នាំ២០០៨

នៅឯមជ្ឈមណ្ឌលព័ត៌មានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អាស័យដ្ឋានផ្ទះលេខ ៦A ផ្លូវ២១ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ (ជិតផ្សារកាប់គោ)

សមាជិកគណៈគ្រប់គ្រងគម្រោងរួមមាន ឯកឧត្តម ស៊ាន វិសុទ្ធ ប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លោក ចូ ស្សូរ នាយកប្រចាំប្រទេសកម្ពុជានៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងលោក រ៉ាហ្វាអែល ដូចាវ ម៉ូរ៉េនណូ ភារៈធារីនៃប្រតិភូសហគមន៍អឺរ៉ុបប្រចាំនៅកម្ពុជានិងមានវត្តមាននៅក្នុងសន្និសីទសារព័ត៌មាននេះ។

ការត្រួតពិនិត្យត្រូវបានផ្តួចផ្តើមឡើងដោយគណៈគ្រប់គ្រងគម្រោងនិងបានប្រព្រឹត្តទៅកាលពីចុងខែកម្ភៈ ឆ្នាំ២០០៨ ដោយក្រុមអ្នកប្រឹក្សាមកពីក្រុមហ៊ុនដីឡយ ប្រចាំនៅប្រទេសឥណ្ឌានិងមកពីកម្ពុជា។ ការត្រួតពិនិត្យសង្កេតលើគោលការណ៍គ្រប់គ្រងបុគ្គលិកនិងការអនុវត្តរបស់ភាគីកម្ពុជានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយធ្វើការវាយតម្លៃលើ តម្លាភាព គណនេយ្យភាព ការគោរពតាមនិយាមអន្តរជាតិ និងការផ្តល់នូវវិធានការណ៍ដែលមានប្រសិទ្ធភាពនិងស៊ីសង្វាក់គ្នាដើម្បីប្រឆាំងនឹងការគ្រប់គ្រងមិនល្អណាមួយ។

លទ្ធផលទាំងស្រុងដែលមាននៅក្នុងរបាយការណ៍នេះនឹងលើកយកមកបង្ហាញនៅឯសន្និសីទសារព័ត៌មានហើយសេចក្តីសង្ខេបនៃការរកឃើញនានានឹងមានចែកជូននៅពេលនោះ។

-----------------------------------------------

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមក

លោកស្រី ហេឡែន ចារិស តាមរយៈទូរស័ព្ទលេខ ០១២ ៤៨៨ ១៣៤ ឬអ៊ីម៉េល helen.jarvis@eccc.gov.kh

លោក ម៉ែន គឹមសេង តាមរយៈទូរស័ព្ទលេខ ០១២ ៥៥៥ ៦០៥ ឬអ៊ីម៉េល men.kimseng@undp.org